ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ០១

ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៥

សាលដីកា

លេខ : ៩៧

ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | ខិន មុន្នី | ជាប្រធាន |
| ២- | លោក | ស៊ិន ឌីម | ជាចៅក្រម |
| ៣- | លោក | គង់ ភីរុន | ជាចៅក្រម |
| ៤- | លោក | ប្រាក់ គីមសាន | ជាចៅក្រមរបាយការណ៍ |
| ៥- | លោក | ម៉ុង មុន្នីចរិយ៉ា | ជាចៅក្រម |

ក្រឡាបញ្ជី

លោក ស៊ិន ភារៈ

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១១៤"ច" ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦១២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍រវាងៈ

-ដើមចោទលោកឈិត បូរ៉ាវុធ តំណាងដោយលោកមេធាវី ១-លោកឡុង នរិទ្ធ ,២-លោកចាន់ សុខយាង ,៣-លោកស៊ិន ប៊ុណ្ណារិទ្ធ ,៤-លោកឡុង ដារ៉ា ,៥-លោកគា អ៊ីវ ,៦-លោក ហាក់ សៀកលី ៧-លោកឌី ប៊ូរីម៉ា , ៨-លោកសួង ចាន់ថន (គណៈមេធាវី) ។

-និងចុងចម្លើយឈ្មោះប្រធានគណៈមេធាវីថ្មីលោក សួន វិសាល តំណាងដោយលោកមេធាវី ១-លោក កុយ នាម ,២-លោកសរ សូវ៉ាន ,៣-លោកនួ ទេពិរិទ្ធ ,៤-លោកសោម ចន្ទ័ឌីណា , ៥-លោក មួង អារុណ ៦-លោកនុត ទីតូ ,៧-លោកខូវ ចន្ធា ,៨-លោកលីវ សុវណ្ណ ,៩-លោកយ៉ុង ផានិត ។

***សំនិវាទ*** : ប្តឹងបដិសេធលទ្ធផលបោះឆ្នោតក្នុងមហាសន្និបាតគណៈមេធាវី ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៤ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់លោកខូវ ចន្ថា និង លោកសោម ច័ន្ទឌីណា (តំណាងអោយគណៈមេធាវី) ប្ដឹងមិនសុខចិត្តពីសាលដីកាលេខ១១៤"ច" ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ០១ចុះថ្ងៃទី០៦ ខែមករាឆ្នាំ២០០៥របស់តុលាការកំពូល ។

-តាមពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤របស់លោកមេធាវីឡុង និទ្ធ , មេធាវីស៊ុន ប៊ុណ្ណារិទ្ធ , មេធាវី គា អ៊ាវ , មេធាវី ឌី ប៊ូរីម៉ា , មេធាវី សួង ចាន់ថន ,មេធាវី ចាន់ សុខយាង ,មេធាវី ឡុង ដារ៉ា ,មេធាវី ហាក់ សៀកលី ,មេធាវី ឈិត បូរ៉ាវុធ និងមេធាវី គី តិច បានអះអាងថា : នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៤ គណៈមេធាវីបានធ្វើការជ្រើសរើស ប្រធានគណៈមេធាវីអណត្តិទី៦ (២០០៤-២០០៦) និង ជ្រើសរើសសមាជិកក្រុមប្រឹក្សាគណៈមេធាវី អណត្តិទី៤(២០០២-២០០៥) ។ ក្នុងមហាសន្និបាតគណៈមេធាវីនេះ បានប្រព្រឹត្តទៅដោយពុំមានលក្ខណៈ សេរី ,តម្លាភាព ,យុត្តិធម៌ ពុំស្រុបតាមលទ្ធិប្រជាធិបតេយ្យ និង ពុំបានអនុវត្តតាមបទបញ្ជាផ្ទៃក្នុង ដែលក្រុមប្រឹក្សាគណៈមេធាវី បានសំរេចកាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ។

-នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៤ជាថ្ងៃមហាសន្និបាត និងជាពេលវេលាមួយដែលត្រូវហាមឃាត់ ដោយបទបញ្ជាផ្ទៃក្នុង ហើយរាល់ការឃោសនារកសំឡេងឆ្នោតរបស់បេក្ខភាពម្នាក់ៗនោះ បេក្ខភាព លោកសួន វិសាល នៅតែចែកចាយខិតប័ណ្ណឃោសនាដល់សមាជិក សមាជិកាមេធាវីអង្គសន្និបាត ។ ទោះ ជាមានគណៈកម្មការរៀបចំការបោះឆ្នោត ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាគណៈមេធាវី និង មានអ្នក អង្កេតការណ៍ពីគ្រប់ភាគីនៃបេក្ខភាពឈរឈ្មោះជាប្រធានគណៈមេធាវីហើយក៏ដោយ ក៏នៅមានការ បង្គាប់បញ្ជាបែបអាណាធិបតេយ្យពីបុគ្គលមេធាវីមួយចំនួន និង សកម្មភាពរបស់បេក្ខភាពសួន វិសាល មេធាវីជីវ សុងហាក់ ,មេធាវីនុត ទីតូ ,មេធាវីម្ទង អារុណ ,មេធាវីនូ ទេពីរិទ្ធ ដែលពុំមានភារកិច្ចសោះ បានបញ្ជាទៅលើគណៈកម្មការរៀបចំការបោះឆ្នោត ឱ្យធ្វើតាមទំនើងចិត្តរបស់ខ្លួន និង ឆក់យកក្បាល មេក្រូស្រែកចាត់ចែងការងារ រំលោភលើតួនាទីភារៈកិច្ចរបស់គណៈមេធាវី ដែលជាអធិបតីនៃមហាសន្និ- បាត ធ្វើឱ្យអង្គមហាសន្និបាតមានការច្របូកច្របល់ ។

-នៅពេលប្រកាសលទ្ធផលជុំទី១ ឃើញថា បេក្ខភាពរបស់លោកគី តិច ទទួលបានសំលេង១០៣ និង បេក្ខភាពលោកសួន វិសាល ទទួលបានសំលេង៨៨ ជាចំណាត់ទី១ និង ទី២ ដែលត្រូវឈានទៅប្រកួត ប្រជែងនៅជុំទី២ ហើយ នូ ទេពីរិទ្ធ ពុំបានជាប់ជាបេក្ខភាពបន្តនោះ បានទៅឆក់យកក្បាលមេក្រូ ដោយ គ្មានការអនុញ្ញាតពីគណៈកម្មការរៀបចំការបោះឆ្នោត និង គណៈចាត់តាំងកម្មវិធីស្រែកបំពងសំលេងថា "ឥឡូវយើងទាំងអស់គ្នាដឹងហើយថា សំឡេងយើងត្រូវបោះឆ្នោតទៅអ្នកណា" យើងត្រូវធ្វើការនិយាយគ្នា ជាមុន ។ ពេលនោះមេធាវីមួយរូបទៀតឈ្មោះនុត ទីតូ បានស្រែកបន្ថែមថា : "បោះឱ្យ សួន វិសាល" ។ សម្រែកបញ្ជាបែបអាណាធិបតេយ្យនេះបានស្ដែងឱ្យឃើញថា គេបានរៀបចំគំរោងការប្រើប្រាស់ល្បិចកល និង សន្យាទិញទឹកចិត្តគ្នាទៅវិញទៅមកជាស្រេច ។

- ម្យ៉ាងទៀតនៅពេលសំរាកបរិភោគអាហារថ្ងៃត្រង់មុនបោះឆ្នោតជុំទី២ ក្រុមសម្ព័ន្ធភាពរបស់ សួន វិសាល បានដើរបរិហារកេរ្តិ៍ជុំយពីការពិតថា "កុំបោះអោយ គី តិច ព្រោះវាជាមនុស្សពុករលួយបក្ខពួក ផ្ដាច់ការ អាគារគណៈមេធាវីនេះដូរជាមួយមនុស្ស៤នាក់ ។

*សំណូមពរ*

១-ស្នើសុំបដិសេធលទ្ធផលបោះឆ្នោតអាណត្តិទី៦ និង បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគណៈ-មេធាវីមួយរូបជំនួសបង្គ្រប់អាណត្តិទី៤ ក្នុងមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦-១០-២០០៤ ទាំងស្រុកចោលជាអសារបង់ ។

២-សុំដីកាសំរេចការផ្ទេរតំណែងរបស់ប្រធានគណៈមេធាវីអាណត្តិទី៥ ទៅប្រធានគណៈមេធាវីអណត្តិទី៦ ជាបណ្ដោះអាសន្ន ដោយរងចាំការដោះស្រាយចប់ជាស្ថាពរ ។

៣-សុំទុករយៈពេល០៣ខែ បន្ទាប់ពីការសំរេចរបស់តុលាការសំរាប់បេក្ខភាពនីមួយៗរៀបចំឃោសនាឡើងវិញ និង សំរាប់គណៈមេធាវីរៀបចំនីតិវិធីនៃមហាសន្និបាតជាថ្មីបន្តទៀត ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ១១៤"ច" ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលា-ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ របស់ក្រុមមេធាវីបណ្ដឹងឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលបណ្ដឹងឧទ្ធរណ៍ពេលសវនាការ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣-ទទួលពាក្យសុំបំបែកសំណុំរឿង ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៤ និង ពាក្យសុំបើកសវនាការជាសាធារណៈ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់មេធាវីចុងបណ្ដឹងឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខ្វះសនឹងគតិច្បាប់ ។

៤-ទុកជាមោឃៈលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីនៃព្រះរាជា-ណាចក្រកម្ពុជា អាណត្តិទី៦ និង លទ្ធផលនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាគណៈមេធាវីមួយរូបសំរាប់អាណត្តិទី៤ (២០០២-២០០៥) ដែលប្រព្រឹត្តទៅនាពេលមហាសន្និបាតប្រចាំឆ្នាំទី៩ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៤។

៥-សំរេចអោយប្រធានគណៈមេធាវីអាណត្តិទី៥ គឺលោក គី តិច បន្តការដឹកនាំគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាបន្តទៅទៀតសិន រហូតដល់មានប្រធានគណៈមេធាវីថ្មី ដែលបានមកដោយការបោះឆ្នោតត្រឹមត្រូវតាមច្បាប់មកជំនួស ។

៦-ទុកជាមោឃៈរាល់សេចក្ដីសំរេចផ្សេងៗរបស់ប្រធានគណៈមេធាវីអាណត្តិទី៦ ដែលសំរេចក្រោយថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៤ រហូតដល់ពេលនេះ ។

៧-សំរេចទុករយៈពេលបីខែ គិតចាប់ពីថ្ងៃដែលសាលដីកានេះចូលជាស្ថាពរ សំរាប់ធ្វើការឃោសនា និង រៀបចំការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវីអាណត្តិទី៦នេះ ។

៨-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹងចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីការកោះ ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការចំនួន៥.០០០រៀល ។

៩-សាលដីកានេះមានអនុភាពអានុវត្តភ្លាម១ទោះជាមានបណ្ដឹងសាទុក្ខក៏ដោយ ។

១០-សាលដីកានេះជំនុំជំរះជាសម្ងាត់ និង ប្រកាសជាសាធារណៈចំពោះមុខក្រុមមេធាវីដើមបណ្ដឹងឧទ្ធរណ៍ កំបាំងមុខក្រុមមេធាវីចុងបណ្ដឹងឧទ្ធរណ៍ តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់លោកខូវ ចន្ថា និង លោកសោម ច័ន្ទឌីណា (តំណាងអោយគណៈមេធាវី) ប្ដឹងមិនសុខចិត្តពីសាលដីកាលេខ១១៤"ច" ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៥ របស់លោកយុង ជានិត ,នុត ទីតូ កុយ នាម ,ខូវ ចន្ថា ,លើវ សុវណ្ណា , នូ ទេពីរិទ្ធ ។

-បានឃើញសារណាតប ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៥របស់លោកសួង ចាន់ថន ,លោកគាអ៊ាវ ចាន់ សុខយាង ,លោកឌី បូរីម៉ា ,លោកបាក់ សៀកលី ,លោកឡុង ដារ៉ា ,លោកឈិត បូរ៉ាវុធ លោក ឡុង និរន្ទ ។

-បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :ចំពោះវិវាទរឿងក្ដីលទ្ធផលបោះឆ្នោតក្នុងមហាសន្និបាតគណៈមេធាវី ជាដំបូងមហាអយ្យការ ឯកភាពតាមចៅក្រមរបាយការណ៍ ដែលបានលើកឡើងរួចហើយ ។

តំណាងមហាអយ្យការ មិនចាំបាច់លើកទៀតទេ ។ តំណាងមហាអយ្យការយល់ឃើញថា :

១-បញ្ហានេះយើងសង្កេតឃើញថា លទ្ធផល និង និតិវិធីនៃការបោះឆ្នោត បានរៀបចំការចុះបញ្ជីអ្នកណាអោយគេឈរឈ្មោះបោះឆ្នោត ។

២-ការបោះឆ្នោះនេះ នីតិវិធីឈានដល់ទីបញ្ចប់នូវលទ្ធផលតាំងពីដំបូងទីរហូតដល់ការប្រកាសលទ្ធផលរួចហើយ ជាពិសេសលោកគី តិច បានធ្វើបណ្ដឹងឧទ្ធរណ៍ដោយសំអាងការបោះឆ្នោតនេះប្រព្រឹត្តទៅមិនគោរពតាមនីតិវិធីទេ ។ មហាអយ្យការយល់ឃើញថា :យន្តការនីតិវិធីចាប់តាំងពីការចុះបញ្ជីមេធាវីមុនពេលបោះឆ្នោតគណៈមេធាវីចាស់ទទួលយកបានគ្មានបញ្ហាឡើយ ក្រោយមករហូតដល់បោះឆ្នោត ជាប់លោកសួន វិសាល គ្មានបញ្ហាអ្វីដែរ ។ លុះក្រោយមកស្រាប់តែលោកគី តិច ប្ដឹងថាការបោះឆ្នោតគ្មានតម្លាភាព គ្មានយុត្តិធម៌ ។ មហាអយ្យការយល់ឃើញថា ពេលមានឧប្បហេតុក្នុងពេលបោះ

ឆ្នោតប្រធានគណៈមេធាវី និង ក្រុមប្រឹក្សាមេធាវីចាស់មានសិទ្ធិដាក់ការបោះឆ្នោត ហើយយកបទបញ្ជាផ្ទៃក្នុង ហើយអាចដាក់វិន័យលើមេធាវីដែលបានបង្កបញ្ហាក្នុងមហាសន្និបាតនេះ ហេតុអ្វីលោកប្រធានគណៈមេធាវីចាស់ មិនធ្វើតាមបទបញ្ជាផ្ទៃក្នុងដែលគេផ្តល់សិទ្ធិឱ្យលោក ។ ចំពោះការស្រែករបស់ភាគីសួន វិសាល គ្មានឥទ្ធិពលអ្វីលើការបោះឆ្នោតឡើយ ព្រោះការបោះឆ្នោតធ្វើឡើងជាសំងាត់ ។ សូមក្រុមប្រឹក្សាជំនុំជំរះពិចារណាលើបញ្ហានេះ តើអាចទទួលយកបាន រឺមិនទទួលយកបាន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ខូវ ចន្ថា តំណាងអោយលោកសួន វិសាល នៅពេលសវនាការថា : ខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលដោយសារសាលាឧទ្ធរណ៍សំរេចសេចក្តីអគតិបំផុតលើបណ្តឹងរបស់លោកគី តិច ថា យើងខ្ញុំមានចែកលិខិតប័ណ្ណទាំងអស់នេះគ្មានភស្តុតាងទេ ។ សេចក្តីសំរេចរបស់សាលាឧទ្ធរណ៍បដិសេធលទ្ធផលបោះឆ្នោត គឺអគតិហើយខ្ញុំបាទបានលើកឡើងពីបណ្តឹងសាទុក្ខឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ មិនបានពិនិត្យឱ្យច្បាស់ មិនគ្រប់ជ្រុងជ្រោយនៅក្នុងការអនុវត្តន៍កន្លងមក ។ គណៈមេធាវី ចុះបញ្ជីទាំងអស់មានអត្តលេខ ដូចលោកគី តិច បានធ្វើអ្នកទាំងអស់មាននៅក្នុងបញ្ជីគណៈមេធាវីដូចគ្នា។ នៅក្នុងមាត្រា១៤ មិនបានបែងចែកទេ ។ ម្យ៉ាងទៀតលក្ខន្តិកៈមេធាវីពេលបោះឆ្នោតម្តង១ ត្រូវធ្វើបទបញ្ជា ហើយបញ្ជូនឱ្យលោកអគ្គពិនិត្យអ្នកបោះឆ្នោតពេញសិទ្ធិ ឬមិនពេញសិទ្ធិនោះទេ គឺគាត់មិនបានប្តឹងជំទាស់ទេ ដល់ពេលលោកសួន វិសាល គាត់ជាប់ឆ្នោត គាត់ថាបោះឆ្នោតមិនត្រឹមត្រូវ ។ សាលាឧទ្ធរណ៍បដិសេធសេចក្តីសំរេចនៃលទ្ធផលបោះឆ្នោត គឺជាអគតិនៅក្នុងលន្តិកៈ ម្យ៉ាងទៀត ជាជំនុំជំរះអសាធារណៈ គឺជាអគតិដែរ ។ ការសុំបំបែកសំណុំរឿងអោយងាយស្រួលដល់តុលាការទេ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ចុះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកនួ ទេពិរិទ្ធ ជាតំណាងអោយម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការ ថា : ខ្លួនជាតំណាង និង ការពារផលប្រយោជន៍គណៈមេធាវី យើងបានដំណើរការបោះឆ្នោតបាន៦ដងហើយ មានមេធាវីកម្មសិក្សាបោះឆ្នោតរហូតមក ។ តាមមាត្រាទី១៤ សាលាឧទ្ធរណ៍មិនបានយល់ច្បាស់លាស់ទេ ដែលនាំឱ្យគាត់យកមាត្រាទី១៤ នេះមកអនុវត្ត ។ យើងឃើញថា បណ្តឹងនេះគ្មានទំរង់ទេ តាមកាលបរិច្ឆេទធ្វើឱ្យប៉ះពាល់ បាត់សណ្តាប់ធ្នាប់ទាំងអស់ តើលទ្ធផលដែលគាត់ចង់បានរបៀបម៉េច? ម្យ៉ាងទៀតខ្លួនដឹងថា តាំងពីឯកឧត្តមអគ្គ ប្តឹងពីលទ្ធផលនៃការបោះឆ្នោត ខ្លួនឃើញថា ការបោះឆ្នោតបានសំរេចអស់ទៅហើយ ហេតុអ្វីបានជាអគ្គព្រះរាជអាជ្ញាសំរេចរបៀបនេះ។ សេចក្តីសំរេចសាលដីកាសាលាឧទ្ធរណ៍ ទុកជាមោឃៈបួនចំនុច ដែលខ្លួនបានលើកឡើងរួចមកហើយ ។ អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យច្បាប់នេះទៅ ខ្លួនមិនចាំបាច់បកស្រាយទៀតទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសរ សូវ៉ាន ជាមេធាវីតំណាងឱ្យម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការ ថា : ខ្លួនមកនេះដើម្បីការពារផលប្រយោជន៍វិជ្ជាជីវៈរបស់មេធាវីទាំងអស់ ចំណែកខ្លួនចាស់ជាងគេឱ្យខ្លួនធ្វើជាប្រធានកិត្តិយសនៅក្នុងគណៈមេធាវី ខ្លួនមិនដែលមានសោរចូលក្នុងបន្ទប់គណៈមេធាវី គេឱ្យខ្លួននៅតែក្រៅ ។ ម្យ៉ាងទៀតដោយសារខ្លួនជាអ្នកដឹកនាំមេធាវីជាប់បណ្តោះអាសន្ន ចំណែក

ឯលោកតី តិច គាត់ទទួលបេក្ខភាពការសុំចូលជាមេធាវី យើងឃើញថា វាមានការច្របូកច្របល់យ៉ាងខ្លាំង ការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍ សំរេចសេចក្តីមកនេះពុំមានលក្ខណៈត្រឹមត្រូវឡើយ គឺមានភាពលំអៀងទាំងស្រុង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមួង អារុណ ជាមេធាវីតំណាងឱ្យម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការ ថា : ខ្លួនមិនទទួលយកបានទេ ការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលបានសំរេចកន្លងមក សូម្បីតែក្រុមរបស់ខ្លួនការពារលទ្ធផលបោះឆ្នោត មិនបានចូលរួមក្នុងនីតិវិធីក៏ពិតមែន ប៉ុន្តែសារណារបស់ខ្លួនក៏បានដាក់ជូនសាលាឧទ្ធរណ៍ត្រឹមត្រូវតាមច្បាប់ គេបោះត្រាជូនត្រឹមត្រូវ ហើយដាក់ជូនក្រុមប្រឹក្សាជំនុំជំរះទៀត ប៉ុន្តែសាលដីកាសាលាឧទ្ធរណ៍មិនមានយល់ឃើញនៅក្នុងសារណារបស់យើងខ្ញុំបន្តិចទេ ។ ម្យ៉ាងទៀតសូមអង្គសវនាការពិចារណាលើសាលដីកាសាលាឧទ្ធរណ៍ ដែលបានសំរេចអោយលោកតី តិច ដឹកនាំគណៈមេធាវីបន្តរហូតដល់ការបោះឆ្នោតសារជាថ្មីទៀត មិនត្រឹមត្រូវទេ ហើយមិនខុះទេ នៅក្នុងគណៈមេធាវីដែលសាលាឧទ្ធរណ៍អាចសំរេចឱ្យអ្នកដឹងនាំគណៈមេធាវីក្នុងរយៈពេលដែលមានជំលោះទាស់ទែងគ្នា រវាងការបោះឆ្នោតជ្រើសរើសប្រធាននៅក្នុងគណៈមេធាវីអ្នកដែលមានវ័យចំណាស់ជាងគេត្រូវធ្វើការបន្តដំណែងជាបណ្តោះអាសន្ន ។ ចំនុចមួយទៀតនិយាយអំពីការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជ-អាជ្ញា អមសាលាឧទ្ធរណ៍ ដែលប្តឹងឧទ្ធរណ៍លើចំនុចមេធាវីកម្មសិក្សា និង មេធាវីមានបទពិសោធ ខ្លួនសូមចាប់អារម្មណ៍ថា អគ្គព្រះរាជអាជ្ញា មានតួនាទីទូលំទូលាយណាស់ក្នុងការការពារផលប្រយោជន៍ច្បាប់ ។ ម្យ៉ាងទៀតការប្តឹងឧទ្ធរណ៍ធ្វើឡើងដោយពុំបានគិត លោកអគ្គព្រះរាជអាជ្ញាត្រូវបានការពារតាំងពីដើមទីគឺវាកើតចេញពីការសំរេចរបស់គណៈមេធាវី បើយកទស្សនៈមេធាវី មិនមែនចូលជាបទដ្ឋានគតិយុត្តទេត្រូវតែរំលាយនូវលទ្ធផលនៃការបោះឆ្នោតទេ ។ រឿងលទ្ធផលមហាសន្និបាត មាត្រាទី៦២ ផ្តោចទៅលើមាត្រា២៥ ការបកស្រាយ គឺភន្តច្រលំខាងផ្លូវច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសោម ច័ន្ទឌីណា ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការថា : នៅក្នុងការបោះឆ្នោតគណៈមេធាវីទូទាំងប្រទេស ធ្វើឡើងតាមច្បាប់ មានប្រធានមួយរូបដើម្បីធ្វើជាភ្នែក ធ្វើជាច្រមុះ ដើម្បីបោះឆ្នោតអោយមានលទ្ធិប្រជាធិបតេយ្យ ។ ការរៀបចំបោះឆ្នោត គឺបានចាត់តាំងបុគ្គលម្នាក់ដែលមានអាយុច្រើនជាងគេ គឺលោកតា ម៉ម យ៉ែម ។ ពាក់ពាន់ទៅនឹងការធ្វើកំណត់ហេតុនៅពេលអង្គមហាសន្និបាត បានចាប់ផ្តើមចាត់តាំងលិខិតត្រឹមត្រូវ ហើយមហាសន្និបាតធ្វើកំណត់ហេតុច្រើនដង :

១-អ្នកចុះហត្ថលេខាលើកំណត់ហេតុ

២-មានលក្ខណៈត្រឹមត្រូវ

៣-វាយកុំព្យូទ័រត្រឹមត្រូវ ហើយទាំងបីនេះមានខ្លឹមសារតែមួយព្រមទាំងអ្នកធ្វើកំណត់ហេតុ ។ ការបោះឆ្នោតនេះប្រព្រឹត្តទៅដោយរលូន ហើយបេក្ខភាពដែលឈរឈ្មោះបោះឆ្នោតនេះ សុទ្ធតែចាត់តាំងអ្នកសង្កេតការណ៍ឱ្យចូលរួមសង្កេតការណ៍បោះឆ្នោត ជ្រើសរើសប្រធានគណៈមេធាវីអាណត្តិថ្មីនេះ ។ ការ

បោះឆ្នោតជ្រើសរើសគណៈមេធាវី គឺធ្វើឡើងតាមរយៈមហាសន្និបាតដែលមានមេធាវីទូទាំងប្រទេសចូលរួម គឺស្របតាមឆន្ទះរបស់ច្បាប់ ។ ការបោះឆ្នោតនៅជុំទី លោកគី តិច បានទទួលសំលេងដល់១០៣ សម្លេង ចំណែកឯលោកសួន វិសាល បានសំលេង៨៨សំលេង ។ ក្រោយមកដល់ជុំទី២ គឺបោះឆ្នោត ដោយអ្នកដែលបានចូលរួមចំណែកមេធាវីផ្ទេរសិទ្ធិមិនត្រូវអនុញ្ញាត្តិអោយបោះឡើយ ។ ពេលនោះសំលេងរបស់លោកគី តិច បាន១០៨ សម្លេង លោកសួន វិសាល ទទួលបាន១២៧ សម្លេង ។ សរុបមកគ្មានហេតុផលណាដែលថា ប្រជាប្រិយភាពលោកគី តិច ត្រូវធ្លាក់នោះទេ ព្រោះសំលេងឆ្នោតរបស់លោកគី តិច កើនពី ១០៣ ទៅដល់១០៨ សម្លេងឯណ្ណោះ ។ ជាកិច្ចបញ្ចប់នេះ អ្វីដែលជាបណ្តឹងរបស់តំណាងយើងខ្ញុំ ត្រូវបានសាលាឧទ្ធរណ៍មិនបានលើកសំអាងហេតុច្បាប់ច្បាស់លាស់ទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកលីវ សុវណ្ណ ជាមេធាវីតំណាងអោយចុងចម្លើយនៅពេលសវនាការថា : ខ្លួនគ្រាន់តែលើកឡើងពីបញ្ហាមេធាវីដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងថា : ក្នុងពេលឃោសនាបោះឆ្នោតទិញទឹកចិត្តមេធាវី ដោយបានជប់លៀងនៅផ្ទលីណា បញ្ហាខាងលើនេះលោកគី តិចផ្ទាល់ក៏បានធ្វើឃោសនារបៀបនេះដែរ ។ អ្វីដែលថាភាគីខ្លួនទិញទឹកចិត្តមេធាវី ខ្លួនសូមឱ្យមេធាវីដើមបណ្តឹងឧទ្ធរណ៍សូមបញ្ជាក់ភស្តុតាងឱ្យបានច្បាស់លាស់ ។ ហើយចំនុចមួយទៀតដែលនាំឱ្យចាប់អារម្មណ៍នោះ សាលាឧទ្ធរណ៍កាត់ក្តីមានភាពលំអៀង និង នីតិវិធីផងដែរ ។ ម្យ៉ាងទៀតសាលាឧទ្ធរណ៍បានបដិសេធសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវីតាំងពីដើមរហូតដល់ចប់ ។ ខ្លួនតំណាងឱ្យផលប្រយោជន៍គណៈមេធាវីសូមសំណូមពរក្រុមប្រឹក្សាជំនុំជំរះពិចារណាទៅលើភស្តុតាង ដែលភាគីដើមបណ្តឹងឧទ្ធរណ៍បានលើកឡើង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកយុង ផានិត ជាមេធាវីតំណាងឱ្យចុងចម្លើយ នៅពេលសវនាការថា : ខ្លួនមិនមានយោបល់អ្វីបន្ថែមទៀតទេ ព្រោះមេធាវីចុងចម្លើយបានលើកឡើងអស់ហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកនុត ទីតូ ជាមេធាវីតំណាងឱ្យចុងចម្លើយ នៅពេលសវនាការថា : ខ្លួនមិនមានអ្វីនិយាយទៀតទេ ព្រោះមេធាវីចុងចម្លើយបានលើកឡើងអស់ហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកគី តិច ជាដើមចោទ នៅពេលសវនាការថា : ខ្លួនសូមបំភ្លឺករណីមួយចំនួនដែលកើតឡើងអំពីលទ្ធផលនៃការបោះឆ្នោតអាណត្តិទី៦ ។ ខ្លួនគ្រាន់តែបំភ្លឺខ្លះបុំណ្ណោះទេ ។ អ្នកដែលប្រព្រឹត្ត គឺជាអ្នកល្មើសច្បាប់ ក្នុងការឃោសនាបោះឆ្នោត គេទុករយៈពេល១ខែទេ សំរាប់ឃោសនាបោះឆ្នោតមុន៤៨ម៉ោង ត្រូវឈប់ឃោសនាបោះឆ្នោត ។ មិនតែប៉ុណ្ណោះការបោះឆ្នោតមានការរញ៉េរញ៉ៃខ្លះកញ្ចក់ក្បាលម៉ែក្រូ ខ្លះទាត់ធាក់គ្នា ខ្លះដើរទៅនេះ ខ្លះដើរទៅនោះ ។ ម្យ៉ាងទៀតសមាជិកយើងទាំងអស់ជាអ្នកច្បាប់ បើភាគីណាមិនសុខចិត្ត យើងមានច្បាប់ប្តឹងឧទ្ធរណ៍ មាត្រា១៧ គេទុកឱ្យ ១៥ថ្ងៃ គេធ្វើសកម្មភាពយ៉ាងណាក៏ដោយ មិនមែនតែច្បាប់លក្ខន្តិកៈមេធាវីទេ ច្បាប់ខ្លះក៏ទុកឱ្យ ២ខែដែរ សរុបមកភាគីយើងខ្ញុំធ្វើតាមច្បាប់ទាំងអស់ ។ ចំពោះការពាក់ពន្ធ័ចំណុចដែលបណ្តឹងរបស់អគ្គ-ព្រះរាជអាជ្ញា អមឡិញមិញ ចៅក្រមរបាយការណ៍ និង អគ្គព្រះរាជអាជ្ញារង បានលើកឡើងថា ខ្លួនមិនបាន

ធ្វើតាមបទបញ្ញាផ្ទៃក្នុងដែលផ្អែកតាមលក្ខន្តិកៈ ដែលបានលើកឡើងទេ ។ បណ្តឹងរបស់ព្រះរាជអាជ្ញា គឺជាបណ្តឹងធ្វើឡើងស្របច្បាប់ យើងមិនអាចក្រឡេកទៅរឿងអតីតកាល ដែលគាត់មិនបានប្តឹង ហើយពេលនោះគាត់ខុស គាត់យល់ព្រមយកអ្វីដែលយើងធ្វើបានកន្លងមកថា ខុសនោះទេ ។ ហើយរឿងនេះថាមានអាជ្ញាយុកាល ដែលកំណត់ថាប្តឹងចូលជាស្ថាពរ ។ បើគាត់យល់ឃើញថា អំពើនោះខុសច្បាប់ គាត់ប្តឹងពេលណាក៏ដោយហើយមិនមែនជាករណីមេធាវីទេ គឺរឿងអ្វីក៏ដោយអគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញា ខេត្តក្រុងអោយតែមានអំពើល្មើស គាត់មានសិទ្ធិប្តឹងភ្លាម ធ្វើបណ្តឹងអាជ្ញា គឺអត់ខុសទេ ។ ម្យ៉ាងទៀតបណ្តឹងរបស់គាត់ផ្អែកទៅលើច្បាប់លក្ខន្តិកៈមេធាវីអគ្គព្រះរាជអាជ្ញាប្តឹងមានលក្ខណៈត្រឹមត្រូវហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកចាន់ សុខយាង ជាមេធាវីតំណាងឱ្យដើមចោទនៅពេលសវនាការថា : ចំណុចមួយដែលខ្ញុំចង់និយាយ គឺគាត់ចុងចម្លើយគាត់លើកឡើងពីបញ្ហាច្បាប់ ហើយយើងទាំងអស់គ្នាជាអ្នកច្បាប់ ហេតុអ្វីក៏ចោទសាលាឧទ្ធរណ៍ជំរះជាសំងាត់ ខុសច្បាប់ បំពានច្បាប់ ប៉ុន្តែគាត់បានលើកច្បាប់ ដែលនៅក្នុងនោះ ច្បាប់បាននិយាយថា ការជំនុំជំរះគណៈមេធាវីត្រូវធ្វើជាសំងាត់ ច្បាប់គណៈមេធាវី បានចែងច្បាស់លាស់ ។ បើអញ្ចឹងការជំនុំជំរះជាសំងាត់របស់សាលាឧទ្ធរណ៍ ដូចអត់មានអ្វីខុសទេ ពីព្រោះច្បាប់បានចែង ធ្វើជាសំងាត់ ហើយអ្នកធ្វើច្បាប់ត្រូវធ្វើតាមច្បាប់ តើត្រូវធ្វើតាមអ្វី? អញ្ចឹងយោបល់ខ្ញុំសូមបន្ថែមប៉ុណ្ណឹង ដែលជាចំណុចខ្វះចន្លោះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកគា អ៊ាវ ជាមេធាវីតំណាងឱ្យដើមចោទនៅពេលសវនាការថា : ខ្ញុំសូមបន្ថែមខ្លះៗទេ ដែលភាគីបណ្តឹងសាទុក្ខបានលើកឡើង :

ចំណុចទី១ ខ្ញុំមានការសោកស្តាយជាងគេ សោកស្តាយត្រង់ថា មេធាវីទាំងអស់ខាងដើមបណ្តឹងសាទុក្ខបានលើកឡើង គាត់និយាយថា គាត់តំណាងឱ្យគណៈមេធាវីដើម្បីផលប្រយោជន៍គណៈមេធាវី ខ្ញុំដូចជាឆ្ងល់ណាស់ គាត់បានលើកឡើង ចុះភាគីខាងចុងបណ្តឹងសាទុក្ខគេក៏ការពារផលប្រយោជន៍គណៈ-មេធាវីដែរ ។

ចំណុចទី២ ការដែលដើមបណ្តឹងសាទុក្ខ ដែលបានលើកឡើងថា លោកគី តិច បានឡើងទៅចាប់ដៃលោកសួន វិសាល ការចាប់ដៃនេះមិនមែនជាការទទួលយកលទ្ធផលបោះឆ្នោតទេ និយាយឱ្យខ្លីគុលាការកំពូល សំរេចអង្គច្បាប់ អញ្ចឹងយើងឃើញថា ការចាប់ដៃគ្នា សន្មត់ថា ជាការទទួលស្គាល់ទេ មិនអាចប្រកែកបាន មិនអាចប្តឹងបានទេ ។

ចំណុចទី៣ ទាក់ទងទៅនឹងបញ្ហាឃោសនាបោះឆ្នោតអានាធិបតេយ្យ មិនមានការប៉ះពាល់ផលប្រយោជន៍ដល់ការបោះឆ្នោត មិនទទួលឥទ្ធិពលពីការបោះឆ្នោត មិនប៉ះពាល់ទេ គេបង្កើតច្បាប់មកធ្វើអ្វីលក្ខខ័ណ្ឌនេះខ្ញុំផ្អែកទៅលើទិន្នន័យការបោះឆ្នោតជុំទី១ គឺលោកគី តិច ឈ្នះដាច់ដល់ពេលចាប់ផ្តើម ជុតពីហ្នឹងទៅលោកគី តិច ចាញ់ប៉ុន្មានសំលេងភ្លាម ។ហើយអ្នកខ្លះទៀតបាននិយាយថា ពួកយើងត្រូវបោះឆ្នោតអោយលោកសួន វិសាល ។ ម្យ៉ាងទៀតដែលចំណុចទាក់ទងនឹងបណ្តឹងរបស់អគ្គព្រះរាជអាជ្ញា ខ្ញុំមិនច្រលំទេ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ប្តឹងតាមមាត្រាច្បាប់ត្រឹមត្រូវ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសួង ចាន់ថន ជាមេធាវីតំណាងអោយដើមចោទនៅពេលសវនាការ ថា : ខ្លួនសូមបញ្ជាក់បន្ថែមបញ្ហាភាពរញ៉េរញ៉ៃក្នុងមហាសន្និបាតលោកសោម ចន្ទឌីណា គាត់ក៏បានទទួលស្គាល់ថា ពេលដែលមហាសន្និបាត មានភាពរញ៉េរញ៉ៃកើតឡើង យើងជាអ្នកច្បាប់ យើងត្រូវអត់ធ្មត់ យើងត្រូវទុកសិទ្ធិ ទុកឱកាសសំរាប់យើងប្តឹង ។ ខ្លួនសូមបញ្ជាក់ថា អាណត្តិមុនលោកសួន វិសាលក៏គាត់បានប្តឹងពីលទ្ធផលនៃការបោះឆ្នោតដែរ គឺប្តឹងក្នុងរយៈពេល១៥ថ្ងៃ ដូចគ្នា មិនមែនប្តឹងភ្លាមទេ គឺច្បាប់ទុកសិទ្ធិឱ្យយើង១៥ថ្ងៃ ។ យើងជាអ្នកច្បាប់ យើងជាអ្នកបង្កភាពអានាធិបតេយ្យ មិនល្អមើលទេ ដូចភាគីលោកសោម ច័ន្ទឌីណា បានលើកឡើងមានភាពរញ៉េរញ៉ៃមែន ។ ចំពោះភាគីខាងខ្លួន បានអត់ធ្មត់មានសិទ្ធិប្តឹងក្នុងរយៈ១៥ថ្ងៃ ។ ខ្លួនសូមបញ្ជាក់បន្ថែមអំពីបណ្តឹងរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ មេធាវីកម្មសិក្សា ដែលអគ្គព្រះរាជអាជ្ញាប្តឹងនោះមានសិទ្ធិបោះឆ្នោត ដែរឬទេ ? បើអញ្ចឹងមាត្រា៨៨ មាត្រា៨៩ បានចែងច្បាស់ហើយ គឺមាត្រា៨៨ ,៨៩ អនុវត្តបានតែត្រឹមតែថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ ។ អញ្ចឹងលទ្ធផលបោះឆ្នោត នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៤ វាក៏លែងដំណើរការ ហើយវាខុសច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឈិត បូរ៉ាវុធ ជាដើមចោទ នៅពេលសវនាការថា : ខ្លួនសូមលើកចំនុចមួយដែលលោកសោម ច័ន្ទឌីណា បានលើកឡើងពីអ្នកសង្កេតការណ៍នៅក្នុងចំណុចនេះ លោកសោម ច័ន្ទឌីណា គាត់លើកឡើងថា នៅក្នុងសកម្មភាពមហាសន្និបាតនេះ គឺមានអ្នកសង្កេតការណ៍ច្បាស់លាស់ហើយ គឺជាការត្រឹមត្រូវ ធ្វើតាមនីតិវិធីច្បាប់ហើយ ប៉ុន្តែខ្លួនសូមបញ្ជាក់ជូនអង្គជំនុំជំរះបញ្ជាក់ពីតួនាទីរបស់អ្នកសង្កេតការណ៍ថ្ងៃនោះ ដែលក្នុងនោះមានខ្លួនម្នាក់ ,លោកខូវ ចន្ថា ម្នាក់ ហើយនឹងលោកជ សម្បត្តិ ជាអ្នកសង្កេតការណ៍ ហើយអ្នកសង្កេតការណ៍ពេលនោះ មិនមែនអ្នកសង្កេតការណ៍ក្នុងសកម្មភាពមហាសន្និបាតគណៈមេធាវីទេ គឺអ្នកសង្កេតការណ៍គ្រាន់តែសង្កេតការណ៍ពីការរាប់សន្លឹកឆ្នោតរបស់បេក្ខភាព ដើម្បីគាំទ្របេក្ខភាពនោះ របស់គណៈកម្មការបោះឆ្នោតទេ ដូច្នេះការលើកឡើងអ្នកសង្កេតការណ៍ ដែលមានហើយធ្វើតាមនីតិវិធីខ្លួនមិនឯកភាពតាមលោកសោម ច័ន្ទឌីណា ទេ ។ ហើយនៅក្នុងចំណុចនេះ ខ្លួនសូមបញ្ជាក់ថា នៅពេលនេះយើងនិយាយអំពីសកម្មភាពរបស់មហាសន្និបាត សកម្មភាពពេលនោះមានភាពអានាធិបតេយ្យ មានការបង្គាប់បញ្ជាពីគណៈកម្មការបោះឆ្នោត ដោយឡែកនៅក្នុងពេលនោះ អង្គសវនាការរបស់តុលាការកំពូលជំនុំជំរះតែអង្គច្បាប់ទេ ខ្លួនមិនបង្ហាញជូនសាក្សីដែលឃើញសកម្មភាពក្នុងមហាសន្និបាតនេះទេ ខ្លួនបានធ្វើសារណាដាក់ជូនក្រុមប្រឹក្សាជំនុំជំរះហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឡុង ដាភ៍ា តំណាងអោយដើមចោទនៅពេលសវនាការថា : ចំពោះបញ្ហាបានលើកឡើងក្នុងសវនាការនេះ រវាងបញ្ហាទំនាស់រវាងគណៈមេធាវីនេះ ខ្លួនសូមលើកឡើងនូវចំនុចសំខាន់១បី :

ទី១-ការជជែកវែកញែករវាងសមាជិកតំណាងទាំងអស់ ខ្លួនគ្រាន់តែលើកចំនុចភាគីចុងចម្លើយ ដើម្បីឱ្យអង្គសវនាការឱ្យបានជ្រាប ដែលភាគីចុងចម្លើយថា ការប្តឹងឧទ្ធរណ៍នេះ គឺជាការបំផ្លាញលទ្ធផលបោះឆ្នោត ដូច្នេះខ្លួនចង់លើកឡើងពីចំណុចខ្លះ គឺការប្តឹងតវ៉ារបស់តំណាងដែលជាសមាជិកមេធាវី ដែល

បានប្តឹងអំពីលទ្ធផលបោះឆ្នោតនេះ គឺគ្រាន់តែចង់បង្ហាញអំពីតម្លាភាពខាងផ្លូវច្បាប់ អោយគណៈមេធាវីថ្ងៃក្រោយធ្វើមហាសន្និបាតអោយមានរបៀបរៀបរយ កុំឱ្យមានភាពរញ៉េរញ៉ៃដូចការបោះឆ្នោត ដែលបានលើកឡើងនៅពេលនេះ ។

ទី២-ការតវ៉ានេះ គឺជាការតវ៉ាសំដែងពីតម្លាភាពខាងផ្លូវច្បាប់ មិនមែនការតវ៉ាការពារមេធាវីណាមួយទេ ។ ដូច្នេះដោយសារច្បាប់តវ៉ានេះ យើងធ្វើក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីថ្ងៃបោះឆ្នោត ។ ដូច្នេះហើយទើបសមាជិកទាំងអស់សំរេចចិត្តថា សំណូមពរឱ្យប្រធានគណៈមេធាវីចាស់ និង ថ្មី នៅស្ងៀមសិនចាំយើងអនុវត្តច្បាប់ ។ ចំពោះការពាក់ព័ន្ធ និង សេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ភាគីខាងលោក សួន វិសាល បានលើកឡើងថា សាលាឧទ្ធរណ៍សំរេចសេចក្តី គឺមានលក្ខណៈអគតិ ក៏ប៉ុន្តែខ្លួនសូមលើកចំណុច តើអោយសាលាឧទ្ធរណ៍សំរេចយ៉ាងណា បើភាគីចុងចម្លើយទាំងអស់មិនព្រមចូលសវនាការ មិនព្រមជជែកវែកញែក តើរឿងនោះវាយ៉ាងម៉េច តើយើងគប្បីជជែកខាងផ្លូវច្បាប់ ព្រោះយើងមានតុលាការដោះស្រាយជាអាជ្ញាកណ្តាលរបស់យើង ។ ហើយបើយើងមិនចូលមិនព្រមជជែកខាងផ្លូវច្បាប់ តើសាលាឧទ្ធរណ៍គាត់សំរេចយ៉ាងម៉េច តើអោយគាត់សំរេចខុសទេ ដឹងវារិតតែធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ទៀត ។

ទី៣-អំពីកំហុស និង ការអូសបន្លាយពេលវេលារហូតមកដល់សព្វថ្ងៃនេះ តើនេះជាកំហុសរបស់អ្នកប្តឹង ឬ ដោយសារកំហុសអ្នកមិនព្រមចូលរួមក្នុងការដោះស្រាយ ជាចុងចម្លើយយើងឃើញថា ប្រសិនបើយើងជជែកគ្នានៅក្នុងសាលាឧទ្ធរណ៍ យើងអាចដោះស្រាយចប់ នៅសាលាឧទ្ធរណ៍និងមានការរៀបចំបោះឆ្នោតជាថ្មីក្នុងរយៈពេល៣ខែ ហើយមិនខូចផលប្រយោជន៍យើងមកដល់ពេលនេះទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ហាក់ សៀកលី ជាមេធាវីតំណាងឱ្យដើមចោទនៅពេលសវនាការថា: ខ្លួនសុំលើកឡើងអំពីលទ្ធផលបោះឆ្នោត ខ្លួនជាសាក្សីម្នាក់ក្នុងរឿងនេះដែរ ព្រោះនៅក្នុងមហាសន្និបាទ ក្រុមប្រឹក្សាខាងគណៈមេធាវី បានសំរេចឱ្យខ្លួនធ្វើជាអ្នកសំរបសំរួលកម្មវិធី ដូច្នេះខ្លួនជាអ្នករៀបចំការងារ ជាអ្នកចាត់ចែង ហើយជាអ្នកសំរេចឱ្យបេក្ខភាពនិមួយៗឡើងឃោសនារហូតដល់ចុងក្រោយ គឺអ្វីដែលអស់លោកបានឡើងថា : ខ្លួនប្រកាសជាឧឡារិកប្រាប់បេក្ខភាពទាំងអស់ឱ្យរក្សាសណ្តាប់ធ្នាប់ គឺការពិតព្រោះថា : ខ្លួនសង្កេតឃើញពេលនោះ មានសភាពរញ៉េរញ៉ៃពុកសកម្មភាពរបស់មេធាវី របស់យើង ហាក់ដូចជាមិនមែនជាមេធាវីអញ្ចឹង ហើយទើបខ្លួនសំរេចចិត្តថា ឡើងទៅប្រកាសសប្រាប់ដល់អស់លោកបេក្ខភាពក្នុងមហាសន្និបាទឱ្យស្ងៀមស្ងាត់ ហើយបើបេក្ខភាពណាមិនសុខចិត្តនិងលទ្ធផលនៃការបោះឆ្នោតនេះគាត់អាចមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ហេតុនេះហើយទើបបេក្ខភាពខាងលោកគី តិច គាត់បានប្តឹងតវ៉ានៅពេលនោះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវីឡុង និរន្ទ មេធាវីតំណាងឱ្យដើមចោទបានធ្វើសេចក្តីសន្និដ្ឋាន នៅពេលសវនាការថា : ខ្លួនគ្មានអ្វីបន្ថែមទៀតទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ឌី ប្ញូរីម៉ា ជាមេធាវីតំណាងឱ្យដើមចោទ បានធ្វើសេចក្តី

សន្និដ្ឋាននៅពេលសវនាការថា ៖ ខ្លួនគ្មានអ្វីមកបញ្ជាក់បន្ថែមទៀតទេ ព្រោះមេធាវី តំណាងដើមចោទបាននិយាយអស់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ចុះ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ក្រុមមេធាវីដើមបណ្តឹងឧទ្ធរណ៍ និង ក្រុមមេធាវីចុងបណ្តឹងឧទ្ធរណ៍
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១៩-១១-២០០៤របស់លោក ខូវ ចន្ថា និង លោក សោម ចន្ទឹឌីណា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍លើកយករឿងក្តីនេះមកជំនុំជំរះជាសម្ងាត់ ដោយអាងហេតុថា៖ មាត្រា៦២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកំណត់ឱ្យធ្វើសវនាការជាសម្ងាត់នោះ គឺជាការភន្តច្រឡំ ពីព្រោះមាត្រា៦២ ស្ថិតក្នុងផ្នែកទី៣ស្តីពីទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើស និង វិធាននៃវិជ្ជាជីវៈ ឬ ប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬ កិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

-យល់ឃើញថា តាមចំណុចទី២នៃមាត្រា២០៩នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណីដែលចែងថា៖ ការបំពាន ឬ ការខ្វះចន្លោះពុំបានបំពេញទំរង់ច្បាប់ ដែលច្បាប់ចាត់ទុកជាមោឃៈ ដូចជាសវនាការមិនបានធ្វើជាសាធារណៈ ជាមូលហេតុអាចឱ្យតុលាការកំពូលសំរេចទុកជាមោឃៈសាលដីការបស់សាលាឧទ្ធរណ៍ហើយបង្វិលសំណុំរឿងទៅឱ្យសាលាឧទ្ធរណ៍ជុំនុំជំរះជាថ្មីឡើងវិញ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យអនុវត្តសាលដីកាភ្លាម១ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយនោះ គឺជាការបំពានទៅលើមាត្រា១៣ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី និង មាត្រា២១៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលមានអានុភាពផងដែរក្នុងរឿងរដ្ឋប្បវេណី។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១១៤ "ច" ចុះថ្ងៃទី១៩-១១-២០០៤របស់សាលាឧទ្ធរណ៍ដែលបានសំរេច សេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់និងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៤៧៦ ចុះថ្ងៃទី១៩-១១-២០០៤របស់លោកខូវ ចន្ថា និងលោកសោម ចន្ទ័ឌីណា ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១១៤ "ច" ចុះថ្ងៃទី១៩-១១-២០០៤របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ០១ ចុះថ្ងៃទី០៦-០១-២០០៥របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩,០០០រៀល ដែលគណៈមេធាវីបានបង់ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំណាយលើការប្រគល់ដីកាកោះចំនួន១៥,០០០រៀល សរុប១៩,០០០រៀល ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥ ។